ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ២ លេខ ២៦ស្ទួន ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៤

# រាជកិច្ច

**រួមមាន ៈ**

ព្រះរាជក្រមលេខ ០៤នស៩៤ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៤

ស្តីពី

**ការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់**

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

# ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រម

## ព្រះរាជក្រមលេខ ០៤ ន.ស.៩៤

### យើង

### ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន
### រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
### និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
### ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើនៅថ្ងៃទី ២៤-០៩-១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩៣
- គណៈរដ្ឋមន្ត្រីបានយល់ព្រមផង

### ប្រកាសអោយប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នាថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំទឹកដីនគរូបនិយកម្ម និង សំណង់ ដូចមានសេចក្តីតទៅនេះ ÷

## ជំពូកទី ១

### កម្មវត្ថុ

**មាត្រា ១.-**

ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ មានកម្មវត្ថុជំរុញអោយមានការរៀបចំ កែលំអទីក្រុងនិងតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាកិច្ចអភិវឌ្ឍន៍សុខដុមនៃប្រទេស ក្នុងស្មារតី :

- គោរពប្រយោជន៍រួមនិងប្រយោជន៍បុគ្គលផង គោរពសិទ្ធិឯកជនផង គោរពបទបញ្ញាច្បាប់ផង និង ត្រួតពិនិត្យការសាងសង់ផង។

- ធានាការអភិវឌ្ឍន៍សំដៅរកលំនឹងរវាងទីក្រុងនិងតំបន់ជនបទ ផ្អែកទៅលើភូមិសាស្ត្រ និង លក្ខណៈពិសេសនៃជនបទនីមួយ ៗ ។

- ធានាលើតំលៃសម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌ និង ធានាការអភិវឌ្ឍនីវិស័យសេដ្ឋកិច្ច វិស័យទេសចរណ៍ និង រក្សាបាននូវគុណភាពបរិដ្ឋាន ។

## មាត្រា ២.-

ច្បាប់រៀបចំទឹកដី នគរូបនីយកម្មនិងសំណង់នេះ ត្រូវសំអាងទៅលើកម្មសិទ្ធិដែលអនុលោមទៅតាមច្បាប់ភូមិបាលបច្ចុប្បន្ន។ ក្នុងករណីដែលច្បាប់ភូមិបាលត្រូវកែប្រែឬផ្លាស់ប្តូរ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិង សំណង់នឹងត្រូវកែច្នៃអោយស្រប ទៅតាមច្បាប់ភូមិបាលនេះដែរ ។

## មាត្រា ៣.-

ដើម្បីសំរេចនូវបំណងដែលបានចែងខាងលើនេះ ត្រូវបង្កើតអោយមានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ដែលមានសមាជិក និងសំណើការតែងតាំង នឹងរៀបចំដោយអនុក្រឹត្យ ។

ចំពោះរាជធានីភ្នំពេញ គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់សំរាប់ក្រុងភ្នំពេញមួយត្រូវបង្កើត ។ គណៈកម្មាធិការនេះដឹកនាំដោយ ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ហើយដែលមានប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងភ្នំពេញ ឬ អភិបាល អភិបាលរង ព្រមទាំងអង្គភាពបច្ចេកទេសដែលមានសមត្ថកិច្ចចូលរួមជាសមាជិកផងដែរ ។ សមាសភាពច្បាស់លាស់ព្រមទាំងដំណើរការនៃ គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ សំរាប់ក្រុងភ្នំពេញត្រូវកំណត់ដោយអនុក្រឹត្យ ។

ចំពោះខេត្ត ក្រុងនានា ត្រូវបង្កើតអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ដែលដឹកនាំដោយអភិបាលខេត្ត ក្រុង និង អង្គភាព បច្ចេកទេសខេត្ត ក្រុង ដែលមានសមត្ថកិច្ចចូលរួមជាសមាជិកផង ។ សមាសភាពច្បាស់លាស់ព្រមទាំងដំណើរការ នៃអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ត្រូវកំណត់ដោយសេចក្តីសំរេចរបស់ ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ក្រោយពីមានការយល់ព្រមរបស់គណៈកម្មាធិការជាតិនេះ ។

# ជំពូកទី ២

## ឯកសារទាក់ទងការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់

**មាត្រា ៤.-**

ឯកសារទាំងឡាយ ដែលទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ត្រូវរៀបចំតាមករណីនីមួយៗ អោយសមស្របទៅតាមស្ថានភាព លក្ខណៈពិសេសនៃទឹកដី ខេត្ត ក្រុង តំបន់ក្នុងស្មារតីការពារដល់បេតិកភណ្ឌ ដល់បរិដ្ឋានការពារធនធានធម្មជាតិ ព្រមទាំងធានាដល់អភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ។

**មាត្រា ៥.-**

គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់រាជធានីភ្នំពេញ ឬ អនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ខេត្ត ក្រុង នីមួយៗ ត្រូវគូសប្លង់គោលដើម្បីធ្វើការរៀបចំនិងអភិវឌ្ឍន៍ នៃរាជធានី ខេត្ត ក្រុងរបស់ខ្លួន ។ ប្លង់គោលនេះត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិ រៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ និង កំណត់ដោយអនុក្រឹត្យ ។

ដើម្បីការពារនូវបេតិកភណ្ឌ ការពារបរិដ្ឋាននិងដើម្បីធានាអភិវឌ្ឍន៍សេដ្ឋកិច្ចចំពោះតំបន់ពិសេសណាមួយដែលគណៈរដ្ឋមន្ត្រីបានកំណត់ គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ មានភារៈរៀបចំប្លង់គោលសំរាប់តំបន់ ពិសេសនោះដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត ។

# ជំពូកទី ៣

## ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់

**មាត្រា ៦.-**

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ត្រូវរៀបចំឡើងសំរាប់រាជធានី ខេត្ត ក្រុង ។ ប្លង់នេះត្រូវមានការគោរពពីសំណាក់ឯកជនក៏ដូច ជាអាជ្ញាធរសាធារណៈក្នុងកិច្ចការសាងសង់របស់ខ្លួន ។

**មាត្រា ៧.-**

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ត្រូវតែបញ្ជាក់អោយច្បាស់លាស់ អំពីតំបន់ដែលត្រូវប្រើប្រាស់សំរាប់ការពារជាតិ សំរាប់កសិកម្ម សំរាប់ពាណិជ្ជកម្ម សំរាប់ឧស្សាហកម្ម សំរាប់សិប្បកម្ម សំរាប់វប្បធម៌ សំរាប់ទេសចរណ៍ សំរាប់សាសនា ព្រមទាំងសំរាប់សំណង់នៃរដ្ឋបាលនិងបរិក្ខារសាធារណៈ ។ ប្លង់នេះកំណត់ផងដែរនូវលទ្ធភាពសំរាប់សាងសង់ ។

**មាត្រា ៨.-**

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ត្រូវគោរពតាមប្លង់គោល ដូចមាន ចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ។

**មាត្រា ៩.-**

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់សំរាប់រាជធានីនិងខេត្ត ក្រុងនិមួយៗ ត្រូវមានការទទួលយល់ព្រមពីគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ រាជធានីឬអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ខេត្ត ក្រុង រួចត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ទៀត ។ ប្លង់ទាំងអស់ត្រូវមានការទទួលគោរពពីឯកជន ក៏ដូចជាអាជ្ញាធរ សាធារណៈទាំងពួងដែរ ។

**មាត្រា ១០.-**

រាជរដ្ឋាភិបាលរៀបចំបទបញ្ញត្តិពិសេសនិងសេវាភាពនគរូបនីយកម្មដើម្បីការពារ និងលើកតម្លៃរមណីដ្ឋាន ឬ អចលនវត្ថុ ណាដែល និង ផ្តល់នូវអត្ថប្រយោជន៍ខាង ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាព ឬ បច្ចេកទេស ។ បញ្ជីអចលនវត្ថុ ឬ រមណីយដ្ឋានទាំងនោះនឹង កំណត់ដោយអនុក្រឹត្យ ។ ការរុះរើ ការផ្លាស់ប្តូរទ្រង់ទ្រាយ និង ការគ្រប់គ្រងអចលនវត្ថុនិងរមណីយដ្ឋានទាំងនោះ ត្រូវកំណត់ដោយច្បាប់ស្តីពីការការពារបេតិកភណ្ឌ ។

បទបញ្ញត្តិពិសេសនិងសេវាភាពនគរូបនីយកម្មដើម្បីការពារនិងលើកតម្លៃរមណីយដ្ឋានឬអចលនវត្ថុដែលផ្តល់ផលប្រយោជន៍ ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាពឬបច្ចេកទេសត្រូវចារឹកក្នុងប្លង់គោលរៀបចំទឹកដី នគរូបនីយកម្មនិងអភិវឌ្ឍន៍ និង ចារឹកក្នុងប្លង់ប្រើប្រាស់ដីធ្លី និង សំណង់ ។

រាជរដ្ឋាភិបាលកំណត់ដោយអនុក្រឹត្យនូវបញ្ជី ចលនវត្ថុដែលមានប្រយោជន៍ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាពនិងបច្ចេកទេស ដើម្បីធានាការគ្រប់គ្រងអចលនវត្ថុទាំងនេះ តាមបញ្ញត្តិ ច្បាប់ស្តីពីការការពារបេតិកភ័ណ្ឌ ។

# ជំពូកទី ៤

## ការងារនិងសំណង់

**មាត្រា ១១.-**

រាល់ការកកាយរុករក ឬ ការស្ទង់ដែលមានការប៉ះពាល់ដល់ខាង ផ្នែកបុរាណវិទ្យា ចាំបាច់ត្រូវមានការ អនុញ្ញាតពីរាជរដ្ឋាភិបាល ។

រាល់ការសាងសង់ ក្នុងករណីជួបប្រទះនូវវត្ថុអ្វីមួយដែលមានអត្ថប្រយោជន៍ ខាងផ្នែកបុរាណវិទ្យា ឬ ប្រវត្តិសាស្ត្រអ្នកទទួលខុសត្រូវការដ្ឋាន ត្រូវមានកាតព្វកិច្ចរាយការណ៍មកអាជ្ញាធរមានសមត្ថកិច្ចអោយបានជ្រាបភ្លាមៗ ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវបញ្ឈប់ផ្អាកសំណង់ជាបន្ទាន់ ។

**មាត្រា ១២ .**

រាល់បុគ្គលឬ ស្ថាប័នឯកជន ក៏ដូចជាអាជ្ញាធរសាធារណៈ ត្រូវហាមឃាត់មិនអោយសាងសង់លើទីធ្លាដែលមានលក្ខណៈជាសាធារណៈដូចតទៅ ÷

- ទីបំរុងទុកទឹកនិងទំនប់ទឹក
- ទីបំរុងជីករ៉ែ និង តំបន់ព្រៃឈើ
- រមណីយដ្ឋានបុរាណវិទ្យា និង ប្រវត្តិសាស្ត្រ
- សួនច្បារ ឧទ្យានសាធារណៈ និង តំបន់អភិវឌ្ឍន៍
- ដីបំរុងទុកសំរាប់ផ្លូវ បំរុងសំរាប់ចំណីផ្លូវ និងដីបំរុងទុកសំរាប់ផ្លូវរថភ្លើង និង អាកាសយានដ្ឋាន
- ទន្លេ សមុទ្រ ព្រែក ស្ទឹងព្រមទាំងឆ្នេរច្រាំង
- ជាទូទៅនៅលើដីទាំងឡាយណាដែលបញ្ញត្តិច្បាប់កំណត់មិនអោយសង់ ។

លក្ខខ័ណ្ឌនៃការគ្រប់គ្រងតំបន់ទាំងនោះ លក្ខខ័ណ្ឌសំណង់ ឬតាំង ទីលំនៅជុនស្រាល បណ្តោះអាសន្ន អនុញ្ញាតបានដោយអនុក្រឹត្យ ។

**មាត្រា ១៣..**

ការងារសាងសង់និងការតាំងទីត្រូវធ្វើឡើងដោយគោរពតាម ឯកសារដែលទាក់ទងនឹងការរៀបចំទឹកដីនគរូបនីយកម្មនិងសំណង់ គោរពតាមប្លង់ គោលដែលមានចែងក្នុងមាត្រា ៤ និង ៥ នៃច្បាប់នេះ ។

**មាត្រា ១៤..**

រាល់ការសាងសង់ រាល់ការកែប្រែទិដ្ឋភាព ឬការកែប្រែការប្រើប្រាស់សំណង់ណាមួយ ត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ។

ពាក្យស្នើសុំអនុញ្ញាតសាងសង់ត្រូវមានឯកសារនិងប្លង់ចាំបាច់ ។ និតិវិធីក្នុងការអនុវត្តមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា១៥.-**

ឯកសារនិងប្លង់ចាំបាច់សំរាប់ភ្ជាប់ពាក្យសុំអនុញ្ញាតសាងសង់សំណង់ធំៗ ត្រូវរៀបចំឡើងដោយស្ថាបត្យករខ្មែរមានសញ្ញាប័ត្រឬជនណាដែលមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច ។

លក្ខខ័ណ្ឌដែលទាមទារអំពីសញ្ញាប័ត្រនិងទាមទារការទទួលស្គាល់ខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៦.-**

ពាក្យសុំអនុញ្ញាតសាងសង់ត្រូវយកមកដាក់សុំ ដោយម្ចាស់កម្មសិទ្ធិដីឬអ្នកបានទទួលសិទ្ធិពីម្ចាស់កម្មសិទ្ធិ ។ ពាក្យសុំអនុញ្ញាត នេះត្រូវមានភ្ជាប់មកជា មួយផងនូវឯកសារបញ្ជាក់អំពីកម្មសិទ្ធិរបស់ម្ចាស់ដី ។

**មាត្រា ១៧.-**

មិនអនុញ្ញាតអោយសាងសង់នូវសំណង់ណាក្នុងលក្ខណៈដែលមិនសមស្របនឹងប្លង់គោលឬប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ។

មិនអនុញ្ញាតអោយសាងសង់ បើគំរោងសាងសង់នោះ មានការប៉ះពាល់ដល់សន្តិសុខសាធារណៈ ប៉ះពាល់ដល់បរិដ្ឋាន ប៉ះពាល់ដល់អនាម័យសាធារណៈ សំណង់ឬអចលនវត្ថុដែលមានសារប្រយោជន៍ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាពបច្ចេកទេស ឬ ប៉ះពាល់ដល់ តំបន់ដែលមានធនធានធម្មជាតិ ។

មិនអនុញ្ញាតអោយសាងសង់ បើសិនជាពុំមានការរៀបចំអោយមានហេដ្ឋារចនាសម្ព័ន្ធឬបរិក្ខារសាធារណៈអោយបានគ្រប់គ្រាន់នឹងគំរោងសំណង់ ដែលសុំ ។

**មាត្រា ១៨.-**

ក្នុងករណីពុំទាន់មានប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ អាជ្ញាធរខេត្តក្រុង ត្រូវបង្កើតគណៈកម្មការ ដើម្បីពិនិត្យពាក្យសុំនិងចេញលិខិតអនុញ្ញាតសាងសង់ ។

**មាត្រា ១៩.-**

ចំពោះគំរោងសំណង់រដ្ឋបាល អង្គភាពដែលស្នើសុំសាងសង់ត្រូវមានការអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ច ។

ការអនុញ្ញាតនោះអាចផ្តល់បានតែចំពោះសំណង់ណាដែលមានលក្ខណៈចាំបាច់សំរាប់ដំណើរការផ្នែករដ្ឋបាល ។

ការអនុញ្ញាតនេះមិនអាចនាំអោយមានការផ្លាស់ប្តូរនូវការប្រើប្រាស់ដីធ្លីដែលបានកំណត់មកហើយ ហើយក៏មិនអាចកែប្រែនូវលក្ខណៈសាធារណៈ និងអត្ថប្រយោជន៍ទូទៅនៃតំបន់នេះឡើយ ។

**មាត្រា ២០.-**

សំណង់ទាំងឡាយណាដែលអ្នកវិនិយោគទុនឯកជនបានសាងសង់នៅលើដីរបស់រដ្ឋស្របតាមកិច្ចសន្យាណាមួយ ត្រូវប្រគល់មកអោយរដ្ឋវិញពេល ផុតកំណត់ចែងក្នុងកិច្ចសន្យានោះ ។

**មាត្រា ២១.-**

បើគ្មានមូលហេតុត្រឹមត្រូវដែលបានបញ្ជាក់ក្នុងច្បាប់នេះ មន្ត្រីរាជការណាដែលប្រកែកមិនព្រមទទួលពិនិត្យពាក្យសុំសាងសង់ ឬចេញលិខិតអនុញ្ញាតសាងសង់ឬប្រឆាំងនឹងការចេញលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេល មួយយ៉ាងយូរ ៤៥ ថ្ងៃទេនោះ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ ។

ក៏ត្រូវផ្តន្ទាទោស ដែរ ចំពោះភ្នាក់ងារណាដែលបានពិនិត្យគំរោង សាងសង់ និង ចេញលិខិតអនុញ្ញាតសាងសង់ដែលមិនស្របនឹងបទបញ្ញត្តិ ។

ភ្នាក់ងារត្រួតពិនិត្យលើសំណង់ដែលពុំបានជំទាស់ ពេលដែលខ្លួន ឃើញសំណង់លើការដ្ឋានណាមួយមិនគោរពតាមគំរោងដែលបានអនុញ្ញាត ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ ។

ទណ្ឌកម្មផ្នែករដ្ឋបាលដែលត្រូវយកមកអនុវត្តចំពោះភ្នាក់ងារដែលមានកំហុសដូចជះនរៀបរាប់ខាងលើនេះ ត្រូវកំណត់ដោយច្បាប់រដ្ឋបាល ។

ចំណែកឯអ្នកសាងសង់ដែលមិនគោរពលិខិតអនុញ្ញាតសាងសង់ទេនោះ នឹងត្រូវទទួលបង្គាប់អោយរុះរើកែសំណង់អោយស្របតាមលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេល ៣០ ថ្ងៃយ៉ាងយូរ គឺចាប់ពីថ្ងៃទទួលលិខិតបញ្ជាផ្លូវការ ។

មន្ត្រីរាជការណាដែលរួមគំនិត នឹងត្រូវដាក់បទចោទប្រកាន់ ចំពោះមុខតុលាការ ។

នៅពេលពិនិត្យឃើញមានសំណង់ខុសឆ្គង ការដ្ឋានត្រូវបញ្ឈប់ ហើយជាយថាហេតុ សំភារៈ និងឧបករណ៍សំណង់នៅទីនោះ ត្រូវទទួលរឹបអូសតាមបង្គាប់តុលាការ ។ ក្នុងករណីដែលអ្នកសាងសង់ទទួលរងគ្រោះដោយមិនមែនជាកំហុសរបស់ខ្លួនអ្នករងគ្រោះអាចប្រើសិទ្ធិរបស់ខ្លួនដើម្បីប្តឹងទៅតុលាការទារជម្ងឺចិត្ត ។

**មាត្រា ២២.-**

ម្ចាស់សំណង់ មុនពេលវាយកំទេចសំណង់របស់ខ្លួនដែលមានស្រាប់ ត្រូវមានលិខិតអនុញ្ញាតរុះរើពីអាជ្ញាធរមានសមត្ថកិច្ចជាមុនសិន ។

បែបបទនៃការរុះរើវាយកំទេចសំណង់នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

ការអនុញ្ញាតអោយរុះរើវាយកំទេចសំណង់អាចត្រូវបដិសេធបាន ក្នុងលក្ខណៈដែលការរុះរើវាយកំទេចសំណង់នោះមានទាក់ទិននឹងបញ្ហាសង្គមកិច្ច បច្ចេកទេសនិងបេតិកភណ្ឌ ដែលរដ្ឋបានកត់ត្រា ។

**មាត្រា ២៣.-**

បទបញ្ញត្តិទាំងឡាយណាដែលមាននៅក្នុងច្បាប់ពីមុន ស្តីពីការរៀបចំទឹកដី នគររូបនីយកម្មនិងសំណង់ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ , នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤

ក្នុងព្រះបរមនាម និង តាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ហត្ថលេខា

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

បានបង្គំទូលថ្វាយ និង ជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី ១ និងទី ២

ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការវប្បធម៌ វិចិត្រសិល្បៈ

រៀបចំដែនដី និង នគររូបនិយកម្ម

ហត្ថលេខា

**វណ្ណ ម៉ូលីវណ្ណ**